# Working Group for Partnerships in Decentralization

## ជីវប្រវត្តិ

ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំនៅខែកុម្ភៈឆ្នាំ២០០២ការធ្វើកំណែទំរង់បានមកដល់នៅក្នុងប្រទេសកម្ពុជា។ ដើម្បីឆ្លើយតបទៅនឹងការផ្លាស់ផ្ទូរនេះអង្គការ អភិវឌ្ឍន៏ជាច្រើនបានសំដែងនូវភាពចាំបាច់ក្នុងការបង្កើតបណ្តាញរឹងមាំរវាងអង្គការសង្គមស៊ីវិលនៅថ្នាក់មូលដ្ឋាន និងក្រុមប្រឹក្សាឃុំថ្មីដែលទើបនិងជាប់ឆ្នោត ។ដើម្បីបំពេញការងារនេះអង្គការស៊ីដសេកម្ពុជាបានសុំអោយមានការរៀបចំសិក្ខាសាលាមួយស្តីពីភាពជាដៃគូក្នុងវិមជ្ឈការដែលរៀបចំឡើងនៅខែមករា ឆ្នាំ ២០០៣។ ជាលទ្ធផលដែលបានមកពីសិក្ខាសាលានេះបានបង្កើតក្រុមការងារមួយហៅថា ***ក្រុមការងារវិមជ្ឈការតាមរយៈភាពជាដៃគូ*** **(WGPD)** បានកំណើដែលសំរបសំរួលដោយអង្គការផេកកម្ពុជា។

## អំពីក្រុមការងារវិមជ្ឈការតាមរយៈភាពជាដៃគូ

***ក្រុមការងារវិមជ្ឈការតាមរយៈភាពជាដៃគូ*** **(WGPD)** ទទួលស្គាល់នូវភាពជោគជ័យនៃការអនុវត្តគោលនយោបាយវិមជ្ឈការគឺអាស្រ័យលើលទ្ធភាពរបស់រដ្ឋាភិបាលមូលដ្ឋានដែលកើតឡើងដោយការបោះឆ្នោត ដែលពួកគេជាអ្នកតំណាង និងដោះស្រាយបញ្ហារបស់ប្រជាពលរដ្ឋជាម្ចាស់ឆ្នោត។ ដើម្បីបំពេញនូវអណត្តិរបស់ខ្លួននេះ រដ្ឋាភិបាលថ្នាក់មូលដ្ឋានត្រូវតែកសាងទំនាក់ទំនងជាមួយគ្រប់អ្នកពាក់ព័ន្ធទាំងអស់ ដោយរាប់បញ្ចូលទាំងអង្គការសង្គមស៊ីវិលផងដែរ ។ក្រុមការធ្វើការស្វែងរកដៃគូដើម្បីៈ

*ការទំនាក់ទំនងអំពីកិច្ចសហប្រតិបតិការរវាងប្រជាពលរដ្ឋនិងអង្គការក្នុងការគៀងគរធនធានសំរាប់អនុវត្តសកម្មភាពជាក់លាក់ណាមួយដើម្បីសំរេចនូវគោលដៅរួម ។*

## គោលដៅរបស់ក្រុមការងារគឺ

*ចូលរួមពង្រឹងវិមជ្ឈការ និងលទ្ធិប្រជាធិបតេយ្យ អភិបាលកិច្ចមូលដ្ឋានតាមរយៈការលើកកំពស់ភាពជាដៃគូជាមួយអ្នកពាក់ព័ន្ធវិមជ្ឈការ នៅគ្រប់កំរិត ដោយតួសបញ្ជាក់ពីភាពជាដៃគូរវាងក្រុមប្រឹក្សាឃុំ និងអង្គការសង្គមស៊ីវិល ។*

## សកម្មភាពរបស់ក្រុមការងារ

សកម្មភាពរបស់ក្រុមការងារគឺធ្វើឡើងដើម្បីធ្វើអោយប្រសើរនូវភាពជាដៃគូ។ ក្នុងនោះរាប់បញ្ចូលទាំងការប្រមូលពតិមាន និងចែកចាយ នូវបទពិសោធន៏ មេរៀនពិសោធន៏ល្អៗរបស់ដៃគូ និង សហប្រតិបតិការក្នុងការរៀបចំនូវព្រឹត្តិការផ្សេងៗនៅថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិកសាងទំនាក់ទំនងជាមួយអ្នកធ្វើគោលនយោបាយវិមជ្ឈការដោយធ្វើផ្ទាល់ជាមួយក្រុមប្រឹក្សាឃុំ និងអង្គការសង្គមស៊ីវិល។

ក្នុងឆ្នាំ ២០០៣ ក្រុមការងារបានរៀបចំសិក្ខាសាលាមួយស្តីពីភាពជាដៃគូ ដែលបានផ្តល់ឱកាសរួមគ្នាជាមួយសមាជិកក្រុមប្រឹក្សាឃុំ និងអង្គការសង្គមស៊ីវិល មកពីថ្នាក់ឃុំដោយបានពិភាក្សា និងរៀនសូត្រពីរបៀបនៃការកសាងភាពជាដៃគូ។ អ្នកចូលរួមបានរៀបចំនូវផែនការសកម្មភាពរបស់ខ្លួន និងអនុវត្តអោយបានសំរេចក្នុងការកសាងភាពជាដៃគូតាមរយៈឧទាហរណ៏ជាច្រើនដែលបានផ្តល់ជូនក្នុងវគ្គសិក្ខាសាលាដោយផ្អែកលើបរិបទនៃប្រទេសកម្ពុជាយើង។

ឥឡូវនេះឈានចូលឆ្នាំទីបីនៃការអនុវត្តសកម្មភាពរបស់ក្រុមការងារជាលទ្ធផលក្រុមការងារបានបង្កើតបានក្រុមពីរផ្សេងទៀតគឺនៅឆ្នាំ២០០៣បានបង្កើតក្រុមការងារ វេទិកាវិមជ្ឈការ**(DFWG)** និងក្រុមការងារកំណែទំរង់ វិមជ្ឈការ និងវិសហមជ្ឈការ**(DDWG)** នៅក្នុងឆ្នាំ២០០៥។ ក្រុមការងារ វេទិកាវិមជ្ឈការ**(DFWG)** បាននឹងកំពុងអនុវត្តសកម្មភាពរបស់ខ្លួនក្នុងការផ្តួចផ្តើមរៀបចំ និងសំរបសំរួលអោយមានវេទិកានៅ

ថ្នាក់ជាតិអោយបានពីរដងក្នុងមួយឆ្នាំ។ រីឯក្រុមការងារកំណែទំរង់ វិមជ្ឈការ និងវិសហមជ្ឈការ(**DDWG**) ជាក្រុមការងារដែលអង្គការសង្គមស៊ីវិលនៅថ្នាក់មូលដ្ឋានបានចូលរួមស្វែងយល់ និងចូលរួមនៅក្នុងដំណើការកំណែទំរង់វិមជ្ឈការ និងវិសហមជ្ឈការ។ មូលដ្ឋានគ្រឹះនៃការជជែកនិងពិភាក្សាគឺជាភាសាខ្មែរ។

ក្រុមការងាររៀបចំការប្រជុំជាទៀតទាត់ និងស្វាគមន៏ចំពោះអង្គការរឺ សមាជិកថ្មីណាដែលមានបំណងចង់ចូលរួមក្នុងក្រុមការងារនេះ ។សកម្មភាពរបស់ក្រុមការងារត្រូវបានផ្តល់មូលនិធិដោយសមាជិកក្រុមការងារ ។បច្ចុប្បន្ននេះក្រុមការងារកំពុងដំណើការរៀបចំបង្កើតឧបករណ៏វាយតំលៃដោយខ្លួនឯងតាមរយ:ការដាក់បញ្ចូលគ្នាទាំងការអនុវត្តរបស់ប្រជាពលរដ្ឋនិងការអនុវត្តការងាររបស់ក្រុមប្រឹក្សាឃុំ ។ក្រុមការងារក៏កំពុងបន្តរការកំនត់នូវ បទពិសោធន៏ និងមេរៀនពីអង្គការដែលជាដៃគូ នៅក្នុងទិសដៅយូរអង្វែងដែលជំរុញ អោយកម្មវិធីជាតិពង្រឹង ទំនាក់ទំនង រវាងក្រុមប្រឹក្សាឃុំ និងអង្គការសង្គមស៊ីវិលនៅមូលដ្ឋាន។

**អង្គការចូលរួមសកម្មមាន:** *CIDSE, Seila/PLG, GTZ, VBNK, BfD, Oxfam GB, CCSP, ADI/CCC, JICA, KID, Pact Cambodia, UNICEF, USAID, Ockenden International, CDRI, SIDA, DFID and Concern Worldwide.*

**ក្រុមការងារសូមស្វាគមន៏ជានិច្ចចំពោះអង្គការទាំងអស់ដែលចាប់អារម្មណ៏ និងចង់ចូលរួមក្នុងក្រុមការងារវិមជ្ឈការតាមរយ:ភាពជាដៃគូ។ សម្រាប់ពតិមានបន្ថែមសូមទាក់ទង លោកផៃ សុខុម៉ារ អង្គការផេក កម្ពុជា ទូរស័ព្ទលេខ ០២៣ ២១៧ ៨៥៥។**